# កំណត់នៃនិពន្ធនាយក

ឧទ័យលេខ២នេះ លាតត្រដាងអំពីការស្រាវជ្រាវច្រើនបែបយ៉ាងផ្សេងៗពីគ្នា អំពីកម្ពុជានិងជុំវិញកម្ពុជាផង។ គ្រាន់តែចោលភ្នែកទៅលើមាតិកា ក៏គេអាចឃើញថា វិជ្ជាខ្មែរនាបច្ចុប្បន្នប្រកបទៅដោយភាពសម្បូណ៌ពិត។ អត្ថបទលើកនេះទាក់ទងទៅវិស័យខុសៗគ្នា មានជាអាទិ៍គឺសិល្បៈ, ប្រវត្តិសាសនា, បុរាណវិទ្យា និងស្ថាបត្យកម្ម, រុក្ខវិទ្យា, នរវិទ្យា ព្រមទាំងអក្សរសាស្ត្រ។

ការសិក្សាដែលយើងបង្ហាញមុនគេ ធ្វើឡើងដោយអ្នកស្រី Elizabeth Guthrie ស្ដីអំពីព្រះធរណីដែលជាទេពីនៃដី ហើយដែលនៅប្រទេសកាន់ព្រះពុទ្ធសាសនាថេរវាទ ពោលគឺភូមា, សៀម និងកម្ពុជា គេជឿថាត្រូវបានព្រះពុទ្ធអង្គយកធ្វើជាសាក្សីនៅពេលដែលមារមកចង់ផ្ចាញ់។ អ្នកនិពន្ធផ្ដោតអារម្មណ៍ជាពិសេសទៅលើប្រការដែលភាពស្ត្រីមាននាទីសំខាន់ក្នុងការគោរពបូជា និងសិល្បៈដែលពាក់ព័ន្ធ។ នេះជាការរួមចំណែកមួយក្នុងការរែកញែកអំពីវិស័យស្ត្រី និងថេរវាទ។

បន្ទាប់មកគឺការសិក្សានៃអ្នកស្រី Miriam Stark អំពីស្ថានីយ៍អង្គរបុរី នៅជំនាន់អន្តរកាលមួយដែលភ្ជាប់បុរេប្រវត្តិមកសម័យប្រវត្តិសាស្ត្រ។ យើងអាចជ្រួតជ្រាបអំពីក្រុមផ្នូរមួយ ដែលបុរាណវិទូនេះបានធ្វើកំណាយ ហើយដែលគាត់យល់ថាមានដំណើរការពីរវាងសតវត្សទី២មុនគ្រិស្ត មកដល់សតវត្សទី៤ នៃគ្រិស្តសករាជ។ ទិន្នន័យផ្សេងៗគ្នានៅទីនោះ សុទ្ធសឹងនាំឲ្យយើងពិចារណាអំពីទំនៀមកប់ខ្មោច (ដែលជនជាតិអាស៊ីអាគ្នេយ៍ដីគោកជំនាន់បុរេប្រវត្តិតែងប្រកាន់យក) ដែលផ្លាស់ប្ដូរមកជាការដុតបូជាសព ហើយដែលខ្មែរនិយមតាំងពីមុនសម័យអង្គរតរៀងមក។ ក្រៅពីបង្ហាញថាអង្គរបុរីជាមណ្ឌលពាណិជ្ជកម្មធំមួយ ហើយជាបណ្ដាញជំនួញរវាងអាស៊ីខាងត្បូងនិងខាងអាគ្នេយ៍ អត្ថបទនេះត្រួសត្រាយផ្លូវមួយសម្រាប់ការសិក្សាផ្នែកនរវិទ្យា ក្នុងវិស័យជំនឿនិងកិច្ចប្រតិបត្តិនាសម័យនោះ។

អត្ថបទទីបីមានឈ្មោះថា *L'architecture et ses modèles en Asie du Sud-Est*។ ទីនេះលោក Jacques Dumarçay បន្តការស្រាវជ្រាវវែងឆ្ងាយរបស់គាត់អំពីការវិវឌ្ឍន៍នៃហេដ្ឋារចនាសម្ព័ន្ធអង្គរ ដោយពិនិត្យលើបញ្ហាប្រើប្រាស់ដីធ្លីនា សម័យអង្គរនិងក្រោយអង្គរ នៅផ្ទៃមួយលាតសន្ធឹងពីថ្នល់បារាយដល់វាលរាជដាក។ ការសិក្សានេះផ្អែកលើការត្រួតពិនិត្យផ្ទាល់ដល់ទីកន្លែងផង ព្រមទាំងលើសិលាចារិកសំស្ក្រិតពាក់ព័ន្ធផង។ គឺជាការរួមចំណែកយ៉ាងសំខាន់មួយក្នុងការជជែករែកញែកទូទៅអំពីទំនាក់ទំនងរវាងនយោបាយទឹក និងការរៀបចំដែនដីអង្គរ។

បន្ទាប់មកអត្ថបទលោក Pascal Royère ជាការពង្រីកគំនិតលោក Jacques Dumarçay អំពីការវិវឌ្ឍន៍នៃស្ថាបត្យកម្មអង្គរឲ្យកាន់តែមានភាពទូលំទូលាយឡើង។ ដើម្បីត្រិះរិះអំពីសំណង់ប្រាសាទបាភួន លោក Royère បកក្រោយបន្តិចមកពិនិត្យសំណង់ប្រាសាទកែវព្រមទាំងលោតមកខាងមុខហួសពីនោះ ដើម្បីពិនិត្យមើលប្រាសាទអង្គរវត្ត។ ទាំងនេះសុទ្ធសឹងនាំឲ្យមានការពិចារណាទូទៅលើការវិវឌ្ឍន៍នៃស្ថាបត្យកម្មជំនាន់អង្គរ។ អ្នកនិពន្ធបង្ហាញឲ្យយើងឃើញអំពីការប្រទាញគ្នារវាងការគោរពទម្លាប់ដែលមានរៀងមក និងការបង្កើតថ្មី។ ចរន្តនិមួយៗសុទ្ធសឹងតែទាក់ទងផ្ទាល់ទៅនឹងសោភណភាពព្រមទាំងបញ្ហាបច្ចេកទេស។ ចរន្តថ្មីដែលចង់បម្រើសោភណភាពថ្មី អាចបង្កើតបញ្ហាបច្ចេកទេសថ្មី រីឯដំណោះស្រាយក៏ត្រូវរិះរកតាមវិធីថ្មី ដែលជួនកាលទាល់តែសម័យក្រោយតមកទៀតទើបរកលំនឹងបាន។

ក្រុមអ្នកនិពន្ធ Arndt Kiesewetter, Hans Leisen និង Esther Plehwe v. Leisen ធ្វើការសិក្សាលើវិស័យថ្មីស្រឡាងមួយ ពោលគឺអំពីបច្ចេកទេសគូរនិងលាបពណ៌នៅសម័យអង្គរនិងក្រោយអង្គរ។ គេពិនិត្យយ៉ាងល្អិតល្អន់នូវថ្នាំពណ៌ដែលសេសសល់នៅប្រាសាទអង្គរវត្ត ខ្លះមានតាំងពីជំនាន់ប្រាសាទនេះកសាងដំបូង ខ្លះទៀតតមកដល់ចុងសតវត្សទី១៦។ ការស្រាវជ្រាវនេះ បើកទស្សនៈយើងឲ្យទូលំទូលាយជាងមុនក្នុងការមើល និងស្ញើចសរសើរប្រាសាទនានា ពោលគឺពុំមែនមានតែស្ថាបត្យកម្មប៉ុណ្ណោះឡើយដែលគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែគឺចម្លាក់ភ្ជាប់និងពណ៌ព្រមគ្នា។

សំណេររបស់លោក តាន់ ប៊ុនស៊ុយ មិនពោលអំពីអង្គរ ឬអំពីអតីតកាលណាមួយឡើយ។ គឺជាការបង្ហាញបញ្ហាមួយនាបច្ចុប្បន្ន។ នៅទសវត្សមុនៗនេះ គេចាប់ផ្ដើមឃើញមានបន្លាម្យ៉ាងហៅថា “ព្រះក្លបយក្ស” ឬ “បន្លាយួន” *(Mimosa pigra L)* មករាតត្បាតលើផ្ទៃទឹកច្រើន

កន្លែង ធ្វើឲ្យខូចខាតរុក្ខជាតិក្នុងទឹកខ្លះ ហើយជាពិសេសបញ្ចៀសមច្ឆាជាតិមិនឲ្យផ្តុំគ្នារស់នៅបាន។ អ្នកនិពន្ធលាតត្រដាងពីស្ថានភាពស្រដៀងគ្នានៅតំបន់នានាលើលោក ដើម្បីរកដំណោះស្រាយឲ្យបានសមស្រប។

អត្ថបទនៃអ្នកស្រី ហង្ស ចន្ទសោភា និងលោក លឹម ស្រ៊ូ ក៏ពាក់ព័ន្ធនឹងសម័យបច្ចុប្បន្នដែរ។ នេះគឺជាការសិក្សាស្តីពីសង្គម ឬសហគម៍ផ្សេងៗនៅតំបន់អង្គរ ចាប់ពីភ្នំគូលែនចុះមកក្រោមដល់ទន្លេសាប។ អ្នកនិពន្ធពិនិត្យត្រួសៗទៅលើវិស័យបួន៖ ជីវភាព, សិក្សាធិការ, សុខាភិបាល, ជំនឿនិងប្រពៃណី។ សហគមន៍ទាំងនេះ ថ្វីត្បិតតែរបៀបរស់នៅខុសៗគ្នា ក៏តែងប្រាស្រ័យទាក់ទងគ្នាជាប្រក្រតីតាមរយៈជំនួញ, ការដោះដូរ ឬរបររកស៊ីដទៃ ធ្វើឲ្យយើងឃើញអំពីចលនាពាក់ព័ន្ធគ្នានៃសហគមន៍តំបន់អង្គរទាំងមូល។ ការសិក្សានេះស្ថិតនៅក្នុងគម្រោងសិក្សាលំអិតទៅអនាគតស្តីពីការផ្លាស់ប្តូរដ៏ចាប់រហ័សនៃសង្គមដោយសារកំណើនទេសចរណ៍។

អត្ថបទក្រោយគេនៅជំពូកទីមួយនេះទាក់ទងទៅនិងវិស័យវប្បធម៌មួយ ដែលវាតសន្ធឹងផុតពីទឹកដីកម្ពុជាទៅទៀត។ គឺជាបទសម្ភាសន៍ដែលលោក Martin Platt បានធ្វើឡើងជាមួយអ្នកនិពន្ធខ្មែរកាត់កួយម្នាក់ឈ្មោះ Fon Fafang ហើយដែលរស់នៅភូមិភាគឦសាននៃប្រទេសថៃឡង់ដ៏។ លោក Fon Fafang នេះប្រើភាសាខ្មែរ និងសៀមក្នុងសំណេរនានារបស់គាត់។ គាត់ពោលថា សំណេរទាំងនេះជាការពាំនាំពាក្យនៃអ្នកដែលគ្មានឈ្មោះបោះសម្លេង (អ្នកក្រខ្សត់, អ្នកត្រូវគេរំលោភ, អ្នកពុំចេះអក្សរ, អ្នកទទួលការកៀបសង្កត់ផ្នែកនយោបាយនិងផ្នែកវប្បធម៌...)។ ចំពោះគាត់ អ្នកនិពន្ធពុំត្រូវគ្រាន់តែជាកញ្ចក់ឆ្លុះបញ្ចាំងសង្គម និងវប្បធម៌ខ្លួនផ្ទាល់ប៉ុណ្ណោះឡើយ គឺត្រូវថ្លែងលើសផុតអំពីគំនិតចង្អៀតនេះទៅទៀត ដោយបញ្ចូលខ្លួនទៅក្នុងបរិបទវប្បធម៌អន្តរជាតិ ឬសាកលមួយ ដែលការថ្លែងឆ្លើយផ្លាស់ប្តូរគ្នាមាន មែនពិតតាមរយៈស្លាបប៉ាកកា។

នៅក្នុងជំពូក "បកប្រែ" យើងប្រែជាភាសាជាតិនូវអត្ថបទ "Rites de crémation à Bali" នៃលោក Jean Filliozat។ សំណេរសំខាន់ស្តីពីកិច្ចបូជានៅ Bali នេះ រំលឹកឲ្យយើងចងចាំថា ការប្រៀបធៀបប្រពៃណីពីជាតិមួយទៅជាតិមួយជាការចាំបាច់។

ជាទីបញ្ចប់គឺជំពូក "របាយការណ៍" ដែលសុទ្ធសឹងតែជាសំណេរបច្ចេកទេសអំពីលទ្ធផលនៃការស្រាវជ្រាវនិងជួសជុលដែលកំពុងធ្វើនៅតំបន់អង្គរ។ ក្រៅពីការងារដែលបន្តធ្វើអំពីមុនមក មានការងារស្រាវជ្រាវថ្មីៗដូចជាកំណាយដែលសាកលវិទ្យាល័យ Otago (New Zealand) ធ្វើនៅក្នុងបរិវេណប្រាសាទបក្សីចាំក្រុង, ការស្រាវជ្រាវនៃសាលាបារាំងចុងបូព៌ា (EFEO) ស្តីអំពីការរៀបចំដែនដីនៅអង្គរ, ការស្រាវជ្រាវអំពីប្រវត្តិបុរីអង្គរធំដោយ Mission Archéologique Française au Cambodge និងការស្រាវជ្រាវអំពីទន្លេសាបនាបុរេប្រវត្តិដោយសាកលវិទ្យាល័យ Kanazawa (ជប៉ុន)។

## From the Editors

This second issue of *Udaya* brings together a wide variety of current research in and around Cambodia. The table of contents alone is testimony to the rich diversity of contemporary Khmer Studies. Articles range across many disciplines, from art and religious history to archaeology and architecture, botany, anthropology and literature.

The issue opens with Elizabeth Guthrie's study of representations of the Earth Goddess in Theravadin Buddhist contexts in Burma, Thailand and Cambodia. An important figure in Buddhist mythology, Neang Thoranee "bears witness to the Buddha" during a crucial test of his spiritual strength. Looking specifically at women's associations with this frequently represented mythological character, including sponsorship of image production and worship, the author makes an important contribution to contemporary discussions of gender and Theravadin Buddhism.

Next, archaeologist Miriam Stark brings us back in time to the transition from the prehistoric to the historic period at the southern Cambodian site of Angkor Borei. The author reflects, in particular, on recent excavations of an ancient cemetery, thought to have been in use from around the 2$^{nd}$ century B.C. to the 4$^{th}$ c. A.D. Disparate data indicate that the site may shed light on the shift from inhumation, common in prehistoric mainland Southeast Asian practice, to cremation, documented in Cambodia since pre-Angkorian times. While findings increasingly point to the extent and importance of Angkor Borei as an urban center arising through trade between South and Southeast Asia, the cemetery offers fascinating anthropological perspective on the mechanics of this encounter in religious beliefs and practices.

In the third article, Jacques Dumarçay pursues a lifetime of investigation into infrastructural evolution at Angkor, notably as laid out in a recent publication: *L'architecture et ses modèles en Asie du Sud-Est.* In the short piece published here, the author focuses on Angkorian and post-Angkorian land use in the area between the Eastern and the Neak Pean Barays. Complementing detailed field study with stunning epigraphic evidence from ancient Sanskrit texts which record work carried out in Angkorian times, Dumarçay offers valuable grounding to the on-going debate on water exploitation as the basis for urban development at Angkor.

The fourth article in this issue, by Pascal Royère, develops on Dumarçay's reflections in the related realm of Angkorian architectural evolution. Taking the Baphuon as a focal point, Royère looks back at Takeo temple and forward to Angkor Vat to reach insights into Angkorian building tradition. The author reveals a tension between continuity and innovation as goals of esthetic effect engender technical problems and their ad hoc solutions, which become in turn incorporated into new esthetic goals.

In the next article, Arndt Kiesewetter, Hans Leisen and Esther Plehwe v. Leisen venture into the virtually unexplored field of painting technique and color esthetics in Angkorian and post-Angkorian times. Their unprecedented research into paint schemes at Angkor Vat, dating from the temple's foundation in the 12$^{th}$ century to later 16$^{th}$-century renovations and subsequent use, brings significant nuance to our understandings not only of temple appearance but also of the artistic process as involving both sculpture and painting.

The following piece, by Tan Boun Suy, brings us out of Angkor and out of the past to address a contemporary ecological problem: the spread of *Mimosa pigra L*, known as "preah khlop yeak" or "banla yuon." Over past decades this weed has invaded Cambodian freshwaters, eliminating other aquatic plant

species and threatening fish populations. The author examines similar situations and treatment in other world regions in view of proposing an ecologically viable solution for control of *Mimosa pigra L.*

Other contemporary questions are raised in the next article by Hang Chan Sophea and Lim Srou, a study of ways of life in the Siem Reap / Angkor region. Four areas: means of subsistence, education, health and beliefs and traditions, are examined in each of the region's three zones: the Kulen and its foothills to the north, the town of Siem Reap and its periphery on the Angkor plain, and the lacustrine communities to the south. Though there is sufficient difference between these zones to warrant their mutual distinction, it is extensive and varied interaction between the three which is seen to sustain each of them while giving coherence to the region as a whole. This study was born of the pressing need to monitor the impact on resident populations of rapid change in the region, due primarily to an increase in tourism.

The final piece in the first section of this issue returns us to the larger regional context of Southeast Asia. This is an interview held by Martin Platt with Fon Fafang, a contemporary fiction writer of Kui-Khmer heritage in Thailand. Fon Fafang speaks of his mixed origins and language use, his experimentation with Khmer-Thai bilingualism in writing, his commitment to giving voice to the unheard (the poor, the abused, the illiterate, the politically and culturally oppressed...) and, ultimately, of his transcendence of notions of the writer as attached to or representative of a given geographic space to, instead, inhabit the inter-cultural or universal space of writing.

This issue includes a translation into Khmer of Jean Filliozat's "Rites de crémation à Bali." While Udaya focuses on Cambodia, Filliozat's piece stands as testimony to the importance of comparative work in understanding the particular example at hand. The volume concludes with a series of reports from archaeological teams presently carrying out research in the Angkor region. Most groups follow up on work presented in *Udaya* 1. We would like, however, to point out the inclusion of four projects relatively new to Angkor and to Udaya: the University of Otago's prehistoric work at Baksei Chamkrong, the École Française d'Extrême-Orient's territorial management study, the urban development study of the Mission Archéologique Française au Cambodge and Kanazawa University's research on the Tonle Sap in prehistoric times.

## Notes de la rédaction

Dans ce second numéro, *Udaya* rassemble des travaux de recherche d'aujourd'hui sur le Cambodge et autour du Cambodge, dans un large éventail thématique. La table des matières suffit à témoigner de cette diversité. Les articles relèvent de plusieurs disciplines : de l'art et de l'histoire religieuse à l'archéologie en passant par l'architecture, la botanique, l'ethnologie et la littérature.

Nous ouvrons le numéro avec une étude d'Elizabeth Guthrie sur les représentations de la déesse Terre, Neang Thorani, figure cruciale des traditions theravâdin de la Birmanie, de la Thaïlande et du Cambodge, et que le Buddha "prend à témoin" sur la constance de ses pratiques méditatives pour la quête de la Vérité. L'auteur insiste sur l'association au domaine du féminin de cette figure mythologique abondamment représentée, et contribue grandement ainsi, dans les perspectives des études féminines, au débat actuel sur le theravâda.

Ensuite l'archéologue Miriam Stark nous propose un retour en arrière, à la période transitoire entre préhistoire et époque historique, dans le Sud cambodgien, à Angkor Borei. L'auteur nous présente les résultats des récentes fouilles conduites dans un cimetière ancien en usage, croit-on, entre le 2<sup>e</sup> siècle avant JC et le 4<sup>e</sup> siècle AD. Bien qu'épars, ils contribuent à mieux comprendre le passage de l'inhumation, partout pratiquée en Asie du Sud-Est aux temps préhistoriques, à la crémation, attestée au Cambodge dès l'époque pré-angkorienne. Tout en consolidant notre vue sur l'importance d'Angkor Borei comme cité urbaine se développant à travers les échanges entre l'Asie du Sud et l'Asie du Sud-Est., la présence de ce cimetière ouvre, du point de vue anthropologique, de fascinantes perspectives sur le croisement des croyances et pratiques religieuses de ces deux régions.

Dans le troisième article, Jacques Dumarçay poursuit sa longue recherche sur l'évolution des infrastructures à Angkor, consignée notamment dans une récente publication : *L'architecture et ses modèles en Asie du Sud-Est*. Dans le court article publié ici, il centre son étude sur l'utilisation du sol aux époques angkorienne et post-angkorienne dans la région comprise entre le Baray Oriental et le Baray du Neak Pean. Combinant données recueillies sur le terrain et témoignages de l'épigraphie sanskrite, J. Dumarçay nourrit ainsi le débat toujours d'actualité sur la maîtrise de l'eau comme fondement du développement urbain à Angkor.

La quatrième contribution, signée Pascal Royère, prolonge les réflexions de J. Dumarçay sur l'évolution de l'architecture angkorienne. Partant du Baphuon, P. Royère opère un retour vers le Ta Kev, mais aussi une projection vers Angkor Vat, pour mieux se pénétrer de la pensée des bâtisseurs angkoriens. Le double regard fait apparaître un certain dilemme entre continuité et innovation à finalité esthétique. Une telle innovation engendre de nouveaux problèmes techniques et, à leur tour, les solutions apportées fondent une nouvelle esthétique.

Suit l'article de Arndt Kiesewetter, Hans Leisen et Esther Plehwe v. Leisen qui explorent le domaine jusqu'ici méconnu des techniques de la peinture et de l'esthétique picturale aux époques angkorienne et post-angkorienne. Leur recherche sur les traces picturales à Angkor Vat du 12<sup>e</sup> siècle, date de la fondation du temple, et de la fin du 16<sup>e</sup> siècle où il a été rénové, enrichit non seulement notre vue de l'aspect général du temple lui-même, mais aussi notre connaissance sur les procédés artistiques mis au point pour la sculpture-peinture.

Du passé et d'Angkor, l'étude de Tan Boun Suy nous ramène aux temps présents, devant un problème écologique : l'expansion du *Mimosa pigra L*, connu sous le nom de "Preah Khlâp Yeak" ou

"Banla Yuon". Depuis ces dernières décennies, cette plante envahit les eaux douces du Cambodge, éliminant d'autres espèces parmi la faune et la flore aquatiques. L'auteur examine les situations similaires rencontrées dans d'autres régions du monde afin d'apporter les solutions à ce problème.

Un autre sujet d'actualité, étudié dans le texte de Hang Chan Sophea et Lim Srou, concerne les modes de vie dans la région de Siem Reap / Angkor. Quatre domaines -moyens d'existence, éducation, santé, croyances et traditions- sont ici traités. L'étude a été menée dans trois zones géographiques : le plateau des Kulen au nord, la ville de Siem Reap et la plaine environnante, et enfin les villages lacustres au sud. Bien que marquées par des différences souvent notables, ces trois communautés sont suffisamment inter-dépendantes et les échanges suffisamment réguliers pour que la cohésion de l'ensemble de la région soit assurée. La recherche a été motivée par l'urgente nécessité de mesurer l'impact sur la population locale du changement rapide dû en particulier au développement croissant du tourisme.

Le dernier article de la première partie nous emmène dans un contexte plus large de l'Asie du Sud-Est. C'est une interview de Martin Platt avec Fon Fafang, un écrivain contemporain baignant dans la culture kui-khmer en Thaïlande. Fon Fafang parle de ses origines mixtes et de sa pratique du bilinguisme khmer-thai dans ses écrits. Il affirme également son engagement de donner la parole à ceux qui ne l'ont pas (les pauvres, les illettrés, les opprimés politiques et culturels...). Il tient par là à transcender l'idée du confinement de l'écrivain à une sphère géographique donnée, pour porter en lui l'écriture dans un espace universel.

Ce numéro comporte aussi la traduction en khmer d'un article de Jean Filliozat, "Rites de crémation à Bali". Tandis qu'Udaya se concentre sur le Cambodge, le texte de J. Filliozat nous rappelle l'importance des études comparatives, qui nous permettent de prendre le recul nécessaire pour appréhender un problème spécifique.

Le volume se termine avec une série de rapports provenant d'équipes archéologiques travaillant actuellement dans la région d'Angkor. La plupart fait suite à ceux déjà publiés dans *Udaya* 1. On y remarquera quatre projets relativement nouveaux, pour Angkor comme pour notre journal : les recherches préhistoriques à Baksei Chamkrong conduites par l'Université d'Otago, sur l'aménagement du territoire angkorien par l'École Française d'Extrême-Orient, sur l'histoire urbaine d'Angkor Thom par la Mission Archéologique Française au Cambodge, et les recherches sur le Tonlé Sap par l'Université de Kanazawa.